ពេលវេលាឈប់ទាំងឡាយ ដែលត្រូវប៉ះចំថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ត្រូវបានអនុញ្ញាត អោយឈប់តែចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាជំនួស ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋ លេខាធិការដ្ឋានត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថ លេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ : ៤៤ អនក្រ.បក

## ស្តីពីការបង្កើត កងពលធំថ្មើរជើងលេខ ១៥

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ

– យោងតាមសេចក្តីរបស់រាជរដ្ឋាភិបាល លេខ ៤០ សសរ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីសមាហរណកម្មកំលាំងដាច់ខ្លួនខ្មែរក្រហមចូល កងយោធពលខេមរភូមិន្ទ

– យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១** : ត្រូវបានបង្កើតមួយកងពលថ្មើរជើងដោយយកសញ្ញាសំគាល់ជា កងពលធំថ្មើរជើង លេខ ១៥ ដាក់ចំណុះផ្ទាល់យោធភូមិភាគទី ៤ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២_សេចក្តីប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៦

**សេចក្តីប្រកាស លេខ : ០១ សប្រក**

**របស់រាជរដ្ឋាភិបាលកម្ពុជា**

* * *

នៅក្នុងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រៃឈើ ត្រូវបានចាត់ទុកជាភោគទ្រព្យធម្មជាតិមួយយ៉ាងសំខាន់របស់ប្រទេសជាតិ ដែលទាមទារអោយមានជាចាំបាច់នូវការគ្រប់គ្រង និងការថែរក្សាការពារយ៉ាងហ្មត់ចត់បំផុត ។